# ការធ្វើតេស្តកូវីដ-19 ក្នុងរដ្ឋកាលីហ្វូញ៉ា
## នេះអ្វីអ្នកគួរតែដឹង



**ធ្វើតេស្តហើយរក្សាមិត្តគ្រួសារ និងសហគមន៍អ្នកឲ្យមានសុវត្ថិភាព ។**

## នៅពេលណាខ្ញុំត្រូវធ្វើតេស្ត ?

អ្នកត្រូវតែធ្វើតេស្ត មួយរំពេចសម្រាប់កូវីដ-19 **ប្រសិនបើអ្នកជឿថាអ្នកមាន** **រោគសញ្ញាណាមួយ** – មិនថាស្ថានភាពការចាក់ថ្នាំវ៉ាក់សាំងរបស់អ្នកនោះគឺជាអ្វី ។ រោគសញ្ញា កូវីដ-19អាចមានរោគសញ្ញាដូចជាគ្រុនផ្តាសាយ (រួមទាំង "ការហៀរសំបោរ") អាឡែរហ្ស៊ីតាមរដូវឬផ្តាសាយធ្ងន់ ។ តេស្តកូវីដ-19 ក្នុងរដ្ឋកាលីហ្វូញ៉ា គឺមិនអស់លុយចំពោះអ្នកណាដែលត្រូវការវាឡើយ ។

- ប្រសិនបើអ្នកត្រូវបានចម្លងនឹង កូវិដ-19 **និង**ទាន់ បានវ៉ាក់សាំងពេញលេញ ទទួលការធ្វើតេស្តភ្លាមៗ ។ ប្រសិនបើអ្នកតេស្តរបស់អ្នកគឺជាអវិជ្ជមាន ការធ្វើតេស្តម្តងទៀត 5-7 ថ្ងៃក្រោយពីថ្ងៃការចម្លង ។ អស់អ្នកដែលមិនទាន់បានចាក់វ៉ាក់សាំងនៅឡើយក៏ត្រូវតែធ្វើតេស្តពេល 1-3 ថ្ងៃមុននឹង 3-5 ថ្ងៃក្រោយពីព្រឹត្តិការណ៍ ដែលមានហានិភ័យខ្ពស់ ។
- ប្រសិនបើអ្នកបានចាក់ថ្នាំវ៉ាក់សាំងពេញលេញនៅពេលត្រូវបានចម្លងអ្នកត្រូវតែធ្វើតេស្ត 5-7 ថ្ងៃក្រោយពី ការនៅក្បែរ នរណាម្នាក់ដែលត្រូវបានគេតេស្តឃើញថាវិជ្ជមានថ្មីៗ ។
- ប្រសិនបើអ្នកបានជាសះស្បើយពីជំងឺកូវីដ-19 ក្នុងរយះពេល 3 ខែចុងក្រោយនេះ ហើយមិនមានរោគសញ្ញាអ្វីថ្មី ចាប់តាំងពីអ្នកទទួលការចម្លងថ្មីៗអ្នកមិនចាំបាច់ធ្វើតេស្តទេ ។
- ធ្វើដំណើរឬ ? អាន ឯកសារអង្គហេតុរបស់យើង ។
- សូម អាន ការណែនាំការធ្វើតេស្តពេញលេញ ។ (សាលាឬកន្លែងធ្វើការរបស់អ្នកអាចមានតម្រូវការការធ្វើតេស្តរបស់គេផ្ទាល់) ។

### កូវីដ-19 អាចធ្វើឲ្យមានអារម្មណ៍ហាក់ដូចជាគ្រុនផ្តាសាយ ឬប្រត្តិកម្មធម្មតា ៖

- គ្រុនឬ រងាញាក់
- ក្អក
- ការដកដង្ហើមខ្លី
- ការពិបាកដកដង្ហើម
- ការហត់
- ការឈឺសាច់ដុំឬខ្លួន
- ការឈឺក្បាល
- ការបាត់បង់រសជាតិថ្មី
- ការបាត់បង់ខ្លិនថ្មី
- ការឈឺ ក
- ការស្ទះតឹង
- ការហៀសំបោ
- ការចង់ក្អួត
- ការក្អួត
- ការរាគ



## តើខ្ញុំអាចធ្វើតេស្តនៅទីណា ?

អ្នកអាចដាក់ពេលណាត់ជួបធ្វើតេស្ត ដោយមិនអស់លុយស្វែងរកគ្លីនិកដែលអាចដើរចូលបានឬ ទិញប្រដាប់ធ្វើតេស្តខ្លួន ពីឱសថស្ថានក្នុងមូលហេតុរបស់អ្នក ។ ស្វែងរកទីតាំងធ្វើតេស្តតាមអនឡាញ ឬទូរស័ព្ទ (833) 422-4255 ឬ 211 ។ សូមចូលទៅ covid19.ca.gov ដើម្បីរៀនយល់ថែមទៀត ។ រៀនថែមទៀតអំពី ប្រភេទតេស្តកូវីដ ។

**ស្កែនកូដ QR ដើម្បីទស្សនាគំណអន្តរកម្មនៅក្នុងក្រដាសផ្សាយនេះ ។**

© 2021, California Department of Public Health

## តើតេស្តក្នុងរដ្ឋកាលីហ្វូញ៉ា គឺមិនអសលុយចំពោះអ្នកណាដែលត្រូវការវាឬ ។

គ្មានការចេញលុយពីហោប៉ៅសម្រាប់ការធ្វើតេស្តចាំបាច់ខាងវេជ្ជសាស្រ្តឡើយ ។ អ្នកផ្តល់ការធ្វើតេស្តនឹងផ្ញើរសំបុត្រទៅការធានារ៉ាប់រងអ្នកដោយផ្ទាល់ ។ ការធ្វើតេស្តគឺមិនអស់លុយនៅ ទីកន្លែងធ្វើតេស្តរដ្ឋ។

## តើខ្ញុំគួរតែបារម្ភអំពីស្ថានភាពអន្តោប្រវេសន៍របស់ខ្ញុំឬទេ ?

ទេ ។ ទីកន្លែងធ្វើតេស្តនឹងមិនសួរអ្នកអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកឡើយ ។

## តើខ្ញុំនឹងទទួលបានលទ្ធផលតេស្តរបស់ខ្ញុំក្នុងប៉ុន្មានថ្ងៃ ?

លទ្ធផលតេស្តតាមធម្មតាត្រឡប់មកវិញ ក្នុងកំឡុង 2-3 ថ្ងៃ ។

## តើខ្ញុំគួរធ្វើដូចម្តេចនៅពេលខ្ញុំរង់ចាំលទ្ធផលរបស់ខ្ញុំ ?

ប្រសិនបើអ្នកមានរោគសញ្ញាឬបាននៅក្បែរនរណាម្នាក់ដែលមានកូវីដ-19 អ្នកត្រូវតែធ្វើចត្តាឡីស័កដើម្បីជៀសវាងពីការរីករាលដាលនៃជម្ងឺ ។ ប្រសិនបើអ្នកត្រូវតែនៅក្បែរមនុស្សដទៃទៀត រួមទាំងគ្រួសារតែងតែពាក់ម៉ាសឬអនុវត្តគន្លាតរាងកាយ ។ ប្រសិនបើអ្នកតេស្តឃើញថាវិជ្ជមានអ្នកនឹងត្រូវបានផ្តល់ការដឹកនាំបន្តទៀតអំពីការព្យាបាល ហើយការញែកខ្លួនពីក្រសួងសុខភាពតាមមូលដ្ឋានរបស់អ្នក ។

## តើកិច្ចគាំទ្រណាដែលរដ្ឋកាលីហ្វូញ៉ា ផ្តល់ក្នុងកំឡុងនៅដាច់ដោយឡែក ឬចត្តាឡីស័កមកពីកូវីដ ?

បុគ្គលមិនអាចធ្វើការបានដោយព្រោះតែកូវីដ-19 ឬនៅក្បែរនរណាម្នាក់ដែលមានជម្ងឺអាច ដាក់ពាក្យសុំទាមទារការធានារ៉ាប់រងអសមត្ថភាព (Disability Insurance, DI) ប្រសិនបើពួកគេមានលិខិតអធ្យាស្រ័យពីអ្នកធ្វើការខាងសុខភាពម្នាក់ ។ បុគ្គលមិនអាចធ្វើការបានដោយព្រោះតែពួកគេកំពុងថែទាំ សម្រាប់សមាជិកគ្រួសារដែលឈឺឬចូលចត្តាឡីស័កដែលមានកូវីដ-19 អាច ដាក់ពាក្យសុំទាមទារការសម្រាកថែទាំគ្រួសារ (Paid Family Leave, PFL) ដើម្បីជួយជាមួយការបាត់បង់ប្រាក់ឈ្នួល ។ ពួកគេត្រូវតែមានលិខិតអធ្យាស្រ័យពី អ្នកធ្វើការខាងសុខភាព ។

CA NOTIFY

## តើរកឃើញថាវិជ្ជមានចំពោះកូវីដ-19 ?

ជួយបញ្ឈប់ការរីករាលដាលដោយឆ្លើយនឹងទូរស័ព្ទឬ ថិចពីក្រសួងសុខភាពរបស់អ្នក ។ម្យ៉ាងទៀត ប្រសិនបើអ្នកធ្វើឲ្យ CA Notify សកម្មក្នុងទូរស័ព្ទរបស់អ្នកសូមជ្រើសប្រាប់ដោយអនាមិកអស់អ្នកដែលត្រូវបានចម្លងពីអ្នក ។សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ canotify.ca.gov។

ស្កែនកូដ QR ដើម្បីទស្សនាតំណអន្តរកម្មនៅក្នុងក្រដាសផ្សាយនេះ ។

ខែកញ្ញា 2021 • © 2021, California Department of Public Health